# ស្ថានភាពព្រៃឡង់



# របាយការណ៍ឃ្លាំមើលលើកទី៨ ដោយ ទិន្នន័យប្រមូលបានពីការចុះល្បាត

- បណ្តាញសហគមន៍ព្រៃឡង់រាយការណ៍អំពីការកាប់ឈើខុសច្បាប់បានកើនឡើង ជាពិសេសនៅជុំវិញរោងម៉ាស៊ីនអារឈើរបស់ក្រុមហ៊ុន ស៊ីងបាយអូតិច

- ភាគច្រើនគឺបានកាប់ឈើប្រភេទជិតផុតពូជ យោងតាមបញ្ជីក្រហមរបស់ IUCN

- យុទ្ធនាការថ្មីរបស់រាជរដ្ឋាភិបាលបង្ក្រាបបទល្មើសព្រៃឈើ គឺត្រូវបានសាទរ បណ្តាញសហគមន៍ព្រៃឡង់បានស្នើរដល់រាជរដ្ឋាភិបាលឲ្យពង្រីកសកម្មភាពបន្ទាន់ បំផុតបង្ក្រាបក្រុមហ៊ុនកាបឈើខុសច្បាប់ជាច្រើននៅក្នុង និងជុំវិញព្រៃឡង់

តាងនាមឲ្យបណ្តាញសហគមន៍ព្រៃឡង់
(PLCN):
Argyriou D.[1], Bori P.[1], Theilade I.[1]

[1] University of Copenhagen



1

# សេចក្តីណែនាំ

រូបភាព២: សមាជិកបណ្តាញព្រៃឡង់ អង្គុយសម្រាកក្នុងពេលធ្វើល្បាត។

ព្រៃឡង់គឺស្ថិតនៅកណ្តាលតំបន់វាលទំនាបនៃប្រទេសកម្ពុជា ភាគខាងលិចទន្លេមេគង្គ។ បានគ្រប ដណ្តប់ផ្ទៃដីព្រៃប្រមាណ ៥០០,០០០ហិតា ហើយមានវិសាលភាពលើខេត្តចំនួន៤ គឺ: ខេត្តក្រចេះ ស្ទឹងត្រែង កំពង់ធំ និងព្រះវិហារ។ ព្រៃនេះបានគាំទ្រដល់ព្រៃប្រពន្ធ័ជីវចម្រុះចំនួន ៧ ប្រភេទខុសគ្នា រួមទាំងព្រៃល្បាប់' ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃស្បាត។ ពូជរុក្ខជាតិ ពូជឈើដែលរងការបាត់បង់ និងពពួកសត្វកម្រ គឺត្រូវបានគេរកឃើញនៅក្នុងព្រៃមួយនេះ។ ព្រៃឡង់គឺជាព្រៃគម្របទឹកភ្លៀងដ៏ចម្បង ចិញ្ចឹមដល់ទន្លេមេគង្គ និងទន្លេសាប ដែលទន្លេទាំងពីរនេះជាផលនៃការនេសាទដល់សហគមន៍មូលដ្ឋាន ដល់សេដ្ឋកិច្ចជាតិ និងសុវត្ថិភាពស្បៀង។ ព្រៃឡង់ គឺបានរក្សាប្រពន្ធ័អាកាសធាតុនៅមូលដ្ឋាន ជួយរក្សាលំនឹង និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុ។ ដោយវាមានសារៈសំខាន់ដល់ប្រទេសជាតិ ព្រៃឡង់បានដាក់ទៅជាតំបន់ដែនជម្រកសត្វព្រៃក្នុងឆ្នាំ២០១៦ មានផ្ទៃដីសរុប ៤៣១, ៦៨៣ហិតា។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ញត្តិដល់ការនាំឈើចេញពីតំបន់នេះ។

បើយោងសាកលវិទ្យាល័យមារីលែន (Maryland២) តំបន់ដែនជម្រកសត្វព្រៃ ព្រៃឡង់ បាត់អស់ផ្ទៃព្រៃឈើប្រមាណ ៤,៥៦៣ហិតា ក្នុងឆ្នាំ២០១៨ (រូបទី១)។ គឺសមាមាត្រទៅនឹងអត្រាមធ្យមគឺបាត់ ១៣ហិតា ជារៀងរាល់ថ្ងៃ ឬស្មើរនឹង ១៨ដង នៃទំហំពហុកីឡាដ្ឋានជាតិអូឡាំពិចភ្នំពេញ (០.៧០៥ហិតា) កាប់ក្នុង១ថ្ងៃៗ។ សាកលវិទ្យល័យម៉ារីលែន ធ្វើការវាស់វែងទិន្នន័យប្រចាំឆ្នាំទៅលើចំនួនដើមឈើដែលបាត់បង់ ប្រៀបធៀបដើមឈើដែលមានរស់ក្នុងទំហុះ ៣០x៣០ ភិកសែលម៉ែត្រ។ វង្វាស់វង្វាល់នេះ គឺមិនបានធ្វើឲ្យខុសគ្នារវាងគម្របផ្ទៃដីអចិន្ត្រៃយ៍ (ការកាប់បំផ្លាញព្រៃឈើ) ឬការបាត់បង់ជាអន្តរកាល (ក្នុងព្រៃដែលនឹងដុះឡើងវិញ) និងមិនរាប់ហេតុដែលបង្ករដោយមនុស្ស ឬធម្មជាតិធ្វើឲ្យបាត់បង់ឡើយ។ បន្ថែមពីលើនេះ ការប្រមូលទិន្នន័យដែលទទួលបានដោយការមើលពីផ្កាយរណប ដែលជារឿយៗបង្ករដោយពពកអ័ព្ទនៃតំបន់ត្រូពិច ពេលខ្លះវាបាត់បង់ក្នុងឆ្នាំនេះ តែអាចប្រមូលក្នុងឆ្នាំបន្ទាប់ ដោយមានការបាំងពពកបន្តបន្ទាប់គ្នា។ អ្នកអង្កេតព្រៃឈើជាសាកល (GFW) បានផ្តល់អនុសាសក្នុងការធ្វើចលនាជាមធ្យមក្នុងរយៈពេលបីឆ្នាំ ដើម្បីប៉ាន់ប្រមាណបរិមាណសរុប ឬនិន្នាការនៃទិន្នន័យគម្របព្រៃឈើបាត់បង់ (បង្ហាញក្នុងរូបភាពទី១)។ ចំនួនព្រៃឈើបាត់បង់សរុបក្នុងកំឡុងឆ្នាំ២០០១ ដល់២០១៨ គឺ៤១,៧៥៨ហិតា ឬប្រហែល ១០% នៃតំបន់ដែនជម្រកសត្វព្រៃ ព្រៃឡង់។

ក្នុងឆ្នាំ ២០០១ សហគមន៍រស់នៅក្នុង និងជុំវិញព្រៃឡង់ បានចាប់ផ្តើមតស៊ូមតិ ការពារដីព្រៃកេរ្តិ៍ដូនតាពីការកាប់បំផ្លាញទ្រង់ទ្រាយធំ និងការរុករានដីធ្លី ដែលជាការបំផ្លាញដល់ការទទួលបាននូវការប្រើ ប្រាស់ធនធានធម្មជាតិរបស់សហគមន៍។ សព្វថ្ងៃនេះ បណ្តាញសហគមន៍ព្រៃឡង់ បានមានការរៀបចំក្រុមសហគមន៍ធ្វើការងារដើម្បីការពារព្រៃឡង់ ដោយមានការសហការជាមួយនឹងអ្នកពាក់ពន្ធ័ជាច្រើន។ បណ្តាញសហគមន៍ព្រៃឡង់ បានធ្វើការល្បាតព្រៃជាទៀងទាត់ដើម្បីប្រមូលពត៌មានពីធនធានព្រៃឈើ សកម្មភាពខុសច្បាប់ និងបម្រែបម្រួលអាកាសធាតុដោយប្រើប្រាស់ទូរសព្ទ័ឆ្លាតវៃ ដែលត្រូវបានគេស្គាល់ថា អែពព្រៃឡង់។ ទិន្នន័យដែលប្រមូលបាន គឺត្រូវបានធ្វើការវិភាគក្នុងការធ្វើសហប្រតិបត្តិការជាមួយនឹងសាកលវិទ្យាល័យកប៉ិនហាហ្គេន (University of Copenhagen) និងលទ្ធផលទាំងអស់ត្រូវបានបោះពុម្ពក្នុងរបាយការណ៍ ធ្វើជាសន្និសីទសារពត៌មាន និងចែកចាយក្នុងប្រពន្ធ័ផ្សព្វផ្សាយ។ វិធីសាស្ត្រថ្មីរបស់បណ្តាញសហគមន៍ព្រៃឡង់ចំពោះការបន្តទៅលើយុត្តិធម៌បរិស្ថាន ដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីអន្តរជាតិ និងទាក់ទាញក្នុងការធ្វើការងារជាបណ្តាញ គឺបានទទួលពានរង្វាន់អន្តរជាតិចំនួនបួនរួចមកហើយ។ ចុងក្រោយបំផុតនោះគឺ ពានរង្វាន់ថាមពលសាកល ២០១៩។

------------------------------

2 Hansen, M. C., P. V. Potapov, R. Moore, M. Hancher, S. A. Turubanova, A. Tyukavina, D. Thau, S. V. Stehman, S. J. Goetz, T. R. Loveland, A. Kommareddy, A. Egorov, L. Chini, C. O. Justice, and J. R. G. Townshend. 2013. "High-Resolution Global Maps of 21st-Century Forest Cover Change." Science 342 (15 November): 850–53. Data available on-line from: *https://earthenginepartners.appspot.com/science-2013-global-forest/download_v1.6.html*. Forest loss for 2018 in Prey Lang Wildlife Sanctuary calculated with Google Earth engine.




1 **រូបភាពទី១:**
ព្រៃឈើបានបាត់បង់ក្នុងព្រៃឡង់ឆ្នាំ ២០០១ ដល់ ២០១៨។ របាពណ៌ខៀវបញ្ឈរបង្ហាញអំពីព្រៃបាត់បង់ប្រចាំឆ្នាំ។ បន្ទាត់ក្រហមបង្ហាញមធ្យមភាគព្រៃបាត់បង់៣ឆ្នាំមកហើយ ។

## ជួបជាមួយនឹងអ្នកល្បាត

លោកស្វាយ សុង កើតក្នុងឆ្នាំ ១៩៥៧។ គាត់ជាជនជាតិដើមភាគតិចកួយ និងរស់នៅក្នុងភូមិតាងួន ឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ ជាមួយប្រពន្ធនិងកូន៦នាក់។ គ្រួសាររបស់គាត់ប្រកបរបរធ្វើស្រែចម្ការ ជាពិសេសគឺស្រូវ និងប្រមូលអនុផលព្រៃឈើ។ លោកសុងបានក្លាយជាសមាជិកសកម្មបណ្តាញព្រៃឡង់ក្នុងឆ្នា២០០០។ លោកបានលះបង់ជីវិតផ្ទាល់ខ្លួនដើម្បីការពារព្រៃឈើ និងជាអ្នកសកម្មក្នុងការគៀងគរសហគមន៍ ការពារព្រៃឡង់ដោយគាត់មានជំនឿថា វាគឺជាទម្រង់នៃភាពចាំបាច់នៃវប្បធម៌ជនជាតិដើមភាគតិចកួយ និងជាជីវិតនៃប្រលឹងវិញ្ញាណ។ ក្នុងឆ្នាំ២០០៩ លោកបានក្លាយជាសមាជិកសកម្មក្នុងឃុំរបស់គាត់ ដោយគាត់មានសមត្ថភាពលើការសហការនិងសហប្រតិបត្តិការនៅក្នុងបណ្តាញនិងជាមួយដៃគូខាងក្រៅជាមួយសមាគមន៍នានា និងជាមួយបណ្តាញ។ លោកបានទទួលការគោរពពីសហគមន៍ និងពីដៃគូខាងក្រៅ ជឿលើជំនាញដែលគាត់មាន អំណាត់ និងការធ្វើការងារធ្ងន់ស្រាលក្នុងកិច្ចការពារព្រៃឈើ។ ក្នុងឆ្នាំ២០១៥ លោកត្រូវបានគេជ្រើសរើសជាមនុស្សម្នាក់ក្នុងចំណោមក្រុមស្នូល២៨នាក់របស់បណ្តាញសហគមន៍ព្រៃឡង់ គាត់ក៏បានមានការគោរពក្នុងនាមជាចាស់ទុំម្នាក់ធ្វើការសហការនិងការបញ្ចូលគ្នានៃបណ្តាញ។ គាត់គឺជាអ្នកសកម្មខ្លាំងបំផុតក្នុងការចូលរួមជាមួយនឹងបណ្តាញសហគមន៍ព្រៃឡង់លើសកម្មភាពតស៊ូមតិ យុទ្ធនាការល្បាត ធ្វើការជាបណ្តាញនិងពង្រឹងសមាជិកភាពតាមមូលដ្ឋាន។



1.1

រូបភាព៣:លោកស្វាយ សុង ក្រុមស្នូលបណ្តាញព្រៃឡង់

# អ្វីដែលថ្មី ចាប់តាំងពីបានធ្វើរបាយការណ៍ត្រួតពិនិត្យចុងក្រោយ



## បណ្ដាញសហគមន៍ព្រៃឡង់ឈ្នះពានរង្វាន់ថាមពលជាតិសម្រាប់ប្រទេសកម្ពុជា

បណ្ដាញសហគមន៍ព្រៃឡង់បានទទួលពានរង្វាន់ថាមពលសាកលក្នុងឆ្នាំ២០១៩ សម្រាប់ការផ្ដួចផ្ដើមថ្មីលើការការពារបរិស្ថាននូវកិច្ចប្រឹងប្រែងក្នុងប្រទេសកម្ពុជា។ ពានរង្វាន់ថាមពលសាកល គឺបានបង្កើតឡើង២០ឆ្នាំហើយ និងវាមានគោលបំណង បង្ហាញនូវគម្រោងជោគជ័យមាននិរន្តរភាពលើមនុស្សជាតិក្នុងសកលលោក និងបង្ហាញនូវដំណោះស្រាយចំពោះបរិស្ថានដែលមាន"។ ពានរង្វាន់អន្តរជាតិថាមពលសកល គឺត្រូវបានគេស្គាល់ថាជា "រង្វាន់ណូបែលរបស់ធម្មជាតិ" មួយនៃចំណោមកិត្យានុភាពរង្វាន់នៃបរិស្ថាន អ្នកដែលឈ្នះត្រូវបានជ្រើសរើសដោយយុត្តិធម៌ ដែលធ្វើឡើងដោយសមាជិកនៃអង្គការសហប្រជាជាតិ អង្គការអភិវឌ្ឍឧស្សាហកម្ម ធនាគារពិភពលោក និងដោយក្រុមប្រឹក្សាកែច្នៃថាមពល អឺរ៉ុប។ បណ្ដាញសហគមន៍ព្រៃឡង់មានការប្រកួតប្រជែងជាមួយនឹង១៨០ប្រទេស ដើម្បីឈ្នះពានរង្វាន់ថាមពលសាកលពិភពលោក២០១៩។

## ការកាប់បំផ្លាញព្រៃឈើ គឺជាកត្តានាំឲ្យមានបម្រែបម្រួលអាកាសធាតុ

បន្ទាប់ពីមានរលកកម្ដៅបោកបក់មកលើតំបន់អាស៊ីអាគ្នេយ៍ និងប្រទេសកម្ពុជាក្នុងកំឡុង ខែមិនា និងមេសា ឆ្នាំ២០១៩ មានពលរដ្ឋជាច្រើនបានប៉ះពាល់ទៅនឹងអាកាសធាតុដ៏អាក្រក់នេះជាមួយនឹងអាកាសធាតុប្រែប្រួល បើយោងទៅតាមការចុះផ្សាយនៃសារពត៌មាន Mongabay ។ សារធារណៈមតិបានរិះគន់ទៅនឹងការកាប់បំផ្លាញព្រៃឈើ ជាមួយនឹងអ្នកនាំពាក្យជាន់ខ្ពស់ដែលបានធ្វើការបដិសេធដោយលោកនេត្រ ភក្ត្រា ជាអ្នកនាំពាក្យនៃក្រសួងបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ បើផ្អែកតាមវិទ្យាសាស្ត្របានបង្ហាញម្ដងហើយម្ដងទៀតនូវការកាប់បំផ្លាញព្រៃឈើ គឺបង្ករដល់ការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើនឧស្ម័នកាបូនិក បំភាយ និងកាត់បន្ថយសំណើម ក៏ដូចជាតាមរយៈសក្ដានុពលប្រែប្រួលវដ្ដនៃទឹក។ ព្រៃឈើបានទាញយកពន្លឺព្រះអាទិត្យដែលចាំងមកលើពួកវា។ តំបន់ដែលគ្មានព្រៃ រួមទាំងដីមានស៊ីម៉ង់រឹងតាមទីក្រុង ឬតំបន់ឧស្សាហកម្ម ដែលជំនួសព្រៃដោយការកំពុងអភិវឌ្ឍ វាបានចាំងពន្លឺត្រឡប់ បង្កើតបានជាកំដៅនៅលើផែនដី។ ម្យ៉ាងវិញទៀត ការបង្ហូតទឹកដោយរស្មីសំយោគគឺអស់១៥% នៃចម្ហាយទឹកនៅក្នុងអាកាស។ មានដើមឈើតិចតួចមានន័យថាមានចម្ហាយទឹកតិច គឺវាជាការលំបាកដល់ការកកើតនៃពពក។ ក្នុងដំណើរការនេះ គឺវាបាននាំទៅរកភាពខ្សោះទឹកភ្លៀង និងមានកម្រិតកម្ដៅកើនឡើង។ ការសិក្សា (study )ថ្មីៗបានបង្ហាញនូវទំនាក់ទំនងរវាងការកាប់បំផ្លាញព្រៃឈើ និងការកើនឡើងនៃកំដៅ ហើយបានរកឃើញទៀតថា ការប្រែប្រួលនៃគម្របព្រៃឈើ គឺជាគន្លឹះទៅរកការប្រែប្រួលអាកាសធាតុក្នុងតំបន់យ៉ាងធំធេង។ លើសពីនេះទៅទៀត ការបំផ្លាញព្រៃឈើជាសាកល នាំទៅរកហានិភ័យនៃកម្រិតសីតណ្ហភាពក្នុងតំបន់ ខណៈដែលអត្រាកើនឡើងនៃការបំផ្លាញព្រៃឈើដូចជានៅក្នុងប្រទេសកម្ពុជា គឺរកឃើញថា បង្កើតបានការគម្រាមគំហែងយ៉ាងខ្លាំង។ ទោះបីជាមានការផ្អាកការកាប់ឈើជាបណ្ដោះអាសន្ន ហាមប្រាមការនាំចេញ និងការបង្ក្រាបបទល្មើសព្រៃឈើ ការធ្វើពាណិជ្ជកម្មព្រៃឈើ ដែលធ្វើដោយរាជរដ្ឋាភិបាល ប្រទេសកម្ពុជានៅតែជាប្រទេសមួយក្នុងពិភពលោក ដែលមានការបំផ្លាញព្រៃឈើ មានអត្រាខ្ពស់ជាងគេ។

------------------------------

3 *https://news.mongabay.com/2019/06/as-cambodia-swelters-climate-change-suspicion-falls-on-deforestation/?n3wsletter&utm_source=Mongabay+Newsletter&utm_campaign=381730ab6a-Newsletter_2019_06_20&utm_medium=email&utm_term=0_940652e1f4-381730ab6a-67238715*

4 Prevedello, J. A., Winck, G. R., Weber, M. M., Nichols, E., & Sinervo, B. (2019). Impacts of forestation and deforestation on local temperature across the globe. PLOS ONE, 14(3). doi:10.1371/journal.pone.0213368

## រាជរដ្ឋាភិបាលបង្ក្រាបការកាប់បំផ្លាញព្រៃឈើ

ការប្រមូលចំណងជើងពីបណ្ដាញសារព័ត៌មានជាតិ និងអន្តរជាតិបានបង្ហាញថា នៅក្នុងខែថ្មីៗនេះ ជាទូទៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានការយកចិត្តទុកដាក់ខ្លាំងឡើង ទៅលើការកាប់ឈើដោយខុសច្បាប់ និងវិនាសកម្មព្រៃឈើ។ ក្នុងខែមករា២០១៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ (លេខាធិការដ្ឋានអចិន្ត្រៃយ៍ថ្នាក់ជាតិដើម្បីបង្ការ និងទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ការដឹកជញ្ជូន ការប្រមូល ការគរទុក និងការនាំចេញឈើប្រណីត) បានទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ដោយមានការផ្ដោតយកចិត្តទុកដាក់ទៅលើឈើប្រណីត។

នៅក្នុងខែថ្មីៗនេះ បានឃើញផងដែរនូវការចាប់មន្ត្រីមួយចំនួន ហើយចោទប្រកាន់ពីបទពុករលួយ នឹងពានិជ្ជករជនជាតិចិនបានរកឃើញពីបទប្រើប្រាស់អាវុធសម្លុតបំភិតបំភ័យ។ គណៈកម្មការចំពោះការបង្ការឧក្រិដ្ឋកម្មព្រៃឈើ បានប្រកាសរិតបន្តឹងនូវយន្តការបន្ទាន់ៗដុតបំផ្លាញរបស់របរដែលរឹមអូសបានពីអ្នកបំផ្លាញព្រៃឈើ។

ភាគីសង្គមស៊ីវិលបានពណ៌នាថា ការបង្កើតស្ថាប័ននានា គឺមានភាពស្រដៀងទៅនឹងការបង្កើតគណៈកម្មការទប់ស្កាត់បទល្មើសព្រៃឈើកាលពីពេលមុនៗ មិនដែលមានដំណោះស្រាយប្រកបដោយប្រសិទ្ធិភាពឡើយ ក្នុងការប្រឆាំងនឹងបទល្មើសព្រៃឈើ ដោយយោងទៅលើអំពើពុករលួយ ហើយអ្នករកស៊ីឈើ គឺជាមនុស្សជិតស្និទ្ធជាមួយនឹងមន្ត្រីរដ្ឋាភិបាល។ ក្រុមអ្នកសកម្មព្រៃឈើបានធ្វើការទាមទារឲ្យរាជរដ្ឋាភិបាលពង្រឹកការបង្ក្រាបលើលក្ខណៈបុគ្គល ទៅជាការបង្រ្កាបក្រុមហ៊ុន ដោយជាញឹកញាប់ក្រុមហ៊ុន គឺជាអ្នកអនុវត្តការកាប់ឈើខុសច្បាប់ ប្រមូលដោយលួចលាក់ បានគម្រាមដល់ការបាត់បងឈើគ្រប់ប្រភេទ។

ក្រុមអ្នកសកម្មព្រៃឈើបានធ្វើការទាមទារឲ្យរាជរដ្ឋាភិបាលពង្រឹកការបង្ក្រាបលើលក្ខណៈបុគ្គល ទៅជាការបង្រ្កាបក្រុមហ៊ុន ដោយជាញឹកញាប់ក្រុមហ៊ុន គឺជាអ្នកអនុវត្តការកាប់ឈើខុសច្បាប់ ប្រមូលដោយលួចលាក់ បានគម្រាមដល់ការបាត់បងឈើគ្រប់ប្រភេទ។

# ភ្នាក់ងារអង្កេតបរិស្ថានបានកោះហៅឲ្យមានចំណាត់ការដល់ប្រទេសវៀតណាម ដែលរំលោភលើសន្ធិសញ្ញា ពាណិជ្ជកម្មអន្តរជាតិនូវប្រភេទឈើកម្រ

ឈើក្រញូងជាប្រភេទឈើប្រណីតដែលដុះនៅក្នុងព្រៃឡង់។ ដោយសារវាមានតម្លៃខ្ពស់ អ្នកកាប់ឈើខុសច្បាប់បានកំពុងកំណត់ឈើប្រភេទនេះជាមុខសញ្ញា នេះបើយោងតាមសេចក្តីរាយការណ៍ម្តងហើយម្តងទៀតដោយក្រុមល្បាតសហគមន៍។ ចាប់តាំងពីឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជាបានចេញប្រកាសហាមប្រាមទៅលើការធ្វើពាណិជ្ជកម្មនូវប្រភេទឈើប្រណីត។ ទោះជាយ៉ាងណាក៏ដោយ ក្នុងខែកញ្ញា២០១៨ សេចក្តីរាយការណ៍របស់ភ្នាក់ងារអង្កេតបរិស្ថានបានកត់សម្គាល់ថាវៀតណាមជាប្រទេសជិតខាង មិនបានធ្វើដឹងឮនូវបម្រាមនាំឈើប្រណីតចេញឡើយ ដែលការនាំចេញខុសច្បាប់ពីប្រទេសកម្ពុជានូវឈើប្រណីតទាំងអស់ គឺបាន (សន្ធិសញ្ញាពាណិជ្ជកម្មអន្តរជាតិនូវប្រភេទឈើកម្រ) ក្លែងនូវការអនុញ្ញាតិ (permits )។

ភ្នាក់ងារអង្កេតបរិស្ថាន បានស្នើរសុំឲ្យមានការបញ្ឈប់ធ្វើពាណិជ្ជកម្មឈើប្រណីតជាមួយ វៀតណាមនិងបានផ្តល់ជាអនុសាសឲ្យប្រទេសវៀតណាមប្រកាសនូវចំនួនឈើដែលបានដឹកចេញពីកម្ពុជា ដើម្បីឲ្យប្រទេសកម្ពុជាមានសមត្ថភាពប្រសើរឡើងក្នុងការទប់ស្កាត់ការធ្វើពាណិជ្ជកម្មខុសច្បាប់នេះ។ របាយការណ៍បានលាតត្រដាងថា ការធ្វើសហប្រតិបត្តិការឆ្លងប្រទេស គឺប្រាកដជានឹងធ្វើឲ្យកើនឡើងនូវការនាំឈើប្រណីតចេញ ហើយនឹងមានការបំផ្លិចបំផ្លាញព្រៃឈើ គម្រាមកំហែងដល់តំបន់ការពារក្នុងប្រទេសកម្ពុជា រួមទាំងព្រៃឡង់ផងដែរ។

## ការថយចុះគម្របព្រៃឈើយ៉ាងលឿននូវដែនជម្រកសត្វព្រៃនៃប្រទេសកម្ពុជា

ចំណងជើងសារព័ត៌មានជាច្រើនក្នុងឆ្នាំ២០១៩ បានរាយការណ៍អំពីការបាត់បង់យ៉ាងឆាប់រហ័ស នៃតំបន់ដែនជម្រកសត្វព្រៃ ក៏ដូចជាការដែលមិនបានគ្រប់គ្រងទៅលើការបំផ្លាញព្រៃឈើយ៉ាងធំធេង, ។ ប្រទេសមួយដែលមានអត្រានៃការបំផ្លាញព្រៃឈើច្រើនជាងគេក្នុងពិភពលោក និងកំពុង គម្រាមកំហែងដល់ដែនជម្រកសត្វព្រៃដែលខ្លួនមាន។ របាយការណ៍បានបង្ហាញនូវដែនជម្រកបឹងពែរបានចាប់ ផ្តើមបាត់បង់ជិត៦០% ក្នុងរយៈពេល២៥ឆ្នាំចុងក្រោយ។ ដូចគ្នានេះដែរ ដែនជម្រកសត្វព្រៃព្រៃឡង់ គឺបានបាត់ប្រមាណជាង១០០គីឡូម៉ែត្រការ៉េនៃគម្របព្រៃឈើក្នុងឆ្នាំ២០១៦។ នៅទូទាំងប្រទេស គឺមានការបាត់បង់ប្រហែល២,០០០គីឡូម៉ែត្រការ៉េក្នុងមួយឆ្នាំៗ ដោយផ្តែកទៅលើហេតុដែលរាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានយ៉ាងធំៗសម្រាប់ក្រុមហ៊ុនធ្វើកសិកម្មក្នុងមួយឆ្នាំៗ ហើយមានភាគច្រើនទៀតដែលក្រុមហ៊ុនបានធ្វើដោយមិនស្របច្បាប់ ។

ដីសម្បទានសេដ្ឋកិច្ច គឺត្រូវបានគេសម្គាល់ថាគឺជាមូលហេតុបឋមនៅពីក្រោយការកាប់បំផ្លាញព្រៃឈើ ដោយមានតម្រវការកើនឡើងនៃការដាំកៅស៊ូ និងប្រភេទឈើប្រណីតដោយការកាប់ព្រៃឈើធម្មជាតិទៅធ្វើជាចំការឈើដាំ។ ទោះជាយ៉ាងណាក៏ដោយ របាយការណ៍នានាបានកំណត់សម្គាល់នូវរបៀបកាប់ឈើធុនមធ្យមគឺបានកាប់ខាងក្រៅជាយតាមព្រំប្រទល់ដីសម្បទាន ដោយប្រើប្រាស់រូបភាពជាការប្រមូលឈើក្នុងដីសម្បទាន។ បញ្ហានេះ គឺមានភាពស្មុគ្រស្មាញដែលត្រូវការការអន្តរាគមន៍ឲ្យបានច្បាស់ៗ។”

------------------------------

5 https://eia-international.org/wp-content/uploads/EIA-report-Vietnam-in-violation-spreads.pdf

6 https://news.mongabay.com/2019/05/illegal-logging-poised-to-wipe-cambodian-wildlife-sanctuary-off-the-map/

7 https://theaseanpost.com/article/cambodias-sanctuaries-under-threat?fbclid=IwAR3d0GBa-JsNOWvQcJDRvJU9pg16vyhpEXxn2Z9PwE_V5Z4pv_1MuPtYvWCc

8 Forest trends: Conversion Timber, Forest Monitoring, and Land-Use Governance in Cambodia, 2015 *https://www.forest-trends.org/publications/conversion-timber-forest-monitoring-and-land-use-governance-in-cambodia/*



## វិធីសាស្ត្រនៃការឃ្លាំមើល

ព្រៃឡង់អែព គឺបានកសាងជាមួយនឹងទិន្នន័យចំហរលើអែពទូរស័ព្ទឆ្លាតវៃនៃអែពសាភីលលី (Sapelli) ដែលបានជួយសម្រួលដល់ការប្រមូលទិន្នន័យដោយប្រើភាសា និងកត់ចំណាំសម្រាប់អ្នកមិនចេះអក្សរ។ អែពព្រៃឡង់កត់ត្រាព្រឹត្តិការណ៍ មានចំណាត់ថ្នាក់បួនយ៉ាង៖

- “**សកម្មភាព**” សំដៅទៅលើសកម្មភាពកាប់បំផ្លាញព្រៃឈើ ដែលកើតមានឡើងក្នុងតំបន់ព្រៃឡង់ ដូចជាកាប់ឈើខុសច្បាប់ កាប់រានដីព្រៃខុសច្បាប់ បរបាញ់ខុសច្បាប់ និងការនេសាទខុសច្បាប់។
- “**ធនធាន**” សំដៅដល់ធនធានធម្មជាតិ ឬធនធានវប្បធម៌ប្រពៃណី និងតំបន់ជំនឿដែលបានរកឃើញនៅក្នុងព្រៃឡង់ ដូចជាដើមច្បោះជ័រ រុក្ខជាតិឱសថ បឹងមានទឹកមានត្រី និងព្រៃជំនឿ។



- “**ការធ្វើសេចក្តីរាយការណ៍**” សំដៅលើចំណាត់ថ្នាក់២យ៉ាង៖ ប្រតិកម្មដោយវិជ្ជមាន (ជាពិសេសគឺជាមួយអាជ្ញាធរ) និងប្រតិកម្មអវិជ្ជមានដូចជាការគម្រាម ឬហិង្សាដល់សមាជិកអ្នកធ្វើល្បាតដែលត្រូវបានកត់ត្រាជាមួយនឹងសមាសភាពសុវត្ថិភាពរបស់អែព។
- “**អាកាសធាតុ**” សំដៅទៅលើការអង្កេតនូវការប្រែប្រួលអាកាសធាតុ ឬយុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលបានអនុវត្តដោយសហគមន៍នៅជុំវិញព្រៃឡង់។

# ផែនទីនៃបណ្ដាញសហគមន៍ព្រៃឡង់ កត់ត្រាជាប់ជាមួយនឹងពេលវេលាជាក់លាក់របស់ផ្កាយរណបនៅជិត ដោយគុណៈកម្មការរបបស់មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអឺរ៉ុប




| | |
|---|---|
| ចំរៀកឈើ | |
| ដង្គត់ឈើ | |
| ការដឹកជញ្ជូនឈើ | |
| តំបន់កាប់ឆ្ការ | |
| បម្រែបម្រួលអាកាសធាតុ | |
| ដីសម្បទានសេដ្ឋកិច្ច | |
| ទីតាំងម៉ាស៊ីនអារឈើ | |
| Delta-rNBR approach | |

## ដែនជម្រកសត្វព្រៃ-ព្រៃឡង់



**រូបភាពទី៤:** ផែនទីបង្ហាញនូវការកត់ត្រាការបញ្ចូលទិន្នន័យពីបណ្ដាញព្រៃឡង់(បានដាក់ពណ៌តាមចំណុច)ប្រៀបធៀបជាមួយនឹងការបំផ្លាញគម្របព្រៃឈើដែលបានរកឃើញដោយឧបករណ៍ FCDM (Langner et al., ២០១៨)សម្រាប់រយៈពេលពីខែមិថុនា ២០១៨ រហូតដល់មិថុនា ២០១៩។ លទ្ធផលទាំងឡាយ FCDM tool Delta-rNBR approach គឺជាផែនទីបានបង្ហាញចំណុចដែលរសើប ដែលបានលើកឡើងនូវក្នុងតំបន់ដែលគម្របព្រៃឈើបានបំផ្លាញគឺត្រូវបានរកឃើញ។ ចំណុចពណ៌ក្រហមដិត គឺជាទំហំដង់ស៊ីតេខ្ពស់ជាងគេនៃការរកឃើញនូវការបំផ្លាញនានា។ ផែនទីនេះកសាងឡើងជាមួយនឹង qGIS ៣.៦.២ Noosa software. ចូរកត់សម្គាល់ថា ការកត់ត្រារបស់បណ្ដាញព្រៃឡង់គឺតំណាងឲ្យការបញ្ចូលចម្រុះ (មើលទៅលើចំណុចពង្រីកនៅក្នុងរូបភាពខាងក្រោម ៤.១ និង ៤.២)

**រូបភាព៤.១និង៤.២** បានពង្រីកពីលើគ្នារវាងទិន្នន័យដែលបញ្ចូលដោយបណ្ដាញសហគមន៍ព្រៃឡង់ និងព្រៃដែលបាត់ដែលបានមើលឃើញដោយឧបករណ៍FCDM (Langner et al., ២០១៨)ដោយប្រើរូបភាពផ្កាយរណបពី Sentinel ១ and Landsat ៧ and ៨

ផែនទីនៅក្នុងរូបភាពទី៤ បង្ហាញពីការកាប់ឈើ និងការប្រែប្រួលអាកាសធាតុ ដែលបណ្ដាញសហគន៍ព្រៃឡង់បានកត់ត្រានៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ និងនៅជុំវិញតំបន់ក្នុងកំឡុងខែមិថុនា ឆ្នាំ២០១៨ ដល់ខែមិថុនា ឆ្នាម២០១៩។ បណ្ដាញសហគមន៍ព្រៃឡង់បានកត់ត្រានូវ២១០សកម្មភាពដោយនិយាមការជីភីអែស ភាគច្រើនគឺជាសកម្មភាពកាប់ឈើខុសច្បាប់ (៨៧%) អ្វីដែលនៅសល់គឺការអង្កេតនូវការប្រែប្រួលអាកាសធាតុដូចជាការថយចុះនៃកម្រិតទឹកនៅក្នុងទន្លេ និងតាមបឹង។ កំណើនឡើងនៃសកម្មភាពកាប់បំផ្លាញព្រៃឈើ គឺអាចអង្កេតឃើញថានៅជុំវិញតំបន់ដីសម្បទាន ជាពិសេសជុំវិញរោងមាស៊ីនរបស់ក្រុមហ៊ុនសិងបាយអូតិចជាប់នឹងទន្លេមេគង្គភាគនារតីខេត្តក្រចេះ។
ទិន្និនរបស់បណ្ដាញសហគមន៍ព្រៃឡង់គឺបានភ្ជាប់ជាលើកដំបូង ទៅនឹងវិធីសាស្ត្រត្រួតពិនិត្យតាមពេលវេលាពិត (ឧបករណ៍FCDM រួមជាមួយនឹងវិធីសាស្ត្រ Delta-rNBR និងវិធីសាស្ត្រDelta-SPE methodology ) ដោយធ្វើការសហការជាមួយគណៈកម្មការរបស់មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវសហគមន៍អ៊ឺរ៉ុប។ លទ្ធផលទិន្នន័យបឋម (ផ្អែកលើ Delta-rNBR methodology តែមួយគត់) ដែលបានបោះពុម្ពនៅឯភ្នាក់ងារសហគមន៍អឺរ៉ុបសំរាប់ពិភពមានជិវិត នាឆ្នាំ២០១៩ នៅមីឡាន (European Space Agency Living Planet Symposium ២០១៩ in Milan ). ឧបករណ៍FCDM (អាចប្រើដើម្បីដំណើរការ Delta-rNBR ក៏ដូចជាវិធីសាស្ត្រ Delta-SPE) ប្រើប្រាស់រូបភាពពីផ្កាយរណបសង្ទីណាល ១ ក៏ដូចជាលែនសាដ ៧និង៨។ លទ្ធផលផែនទីព្រៃឈើដែលបាត់ គឺរាប់នៅក្នុងតំបន់អភិរក្ស គឺបានបង្ហាញចំនួនតិចជាងចំនួនដែលយើងបានឃើញ។ ផែនទីពីរ
ផ្ទាំងក្នុងរូបភាព៤.១ និង៤.២ បង្ហាញការបញ្ចូលទិន្នន័យចម្រុះដែលពង្រីកមកពីផែនទីរូបភាព៤។

------------------------------

9 Langner, A.; Miettinen, J.; Kukkonen, M.; Vancutsem, C.; Simonetti, D.; Vieilledent, G.; Verhegghen, A.; Gallego, J.; Stibig, H.-J. Towards Operational Monitoring of Forest Canopy Disturbance in Evergreen Rain Forests: A Test Case in Continental Southeast Asia. Remote Sens. 2018, 10, 544.

10 Langner, A., et al. Monitoring large- and small-scale changes in vegetation cover in the dry and humid domain using multi-temporal Sentinel-1 data, in preparation

11 Langner, A.; Theilade, I.; Nguyen, K.H.; Berger, D.; Argyriou, D.; Stibig, H.-J. Strengthening forest protection by near real-time forest disturbance monitoring (Delta-rNBR approach) - a case study in Cambodia, ESA Living Planet Symposium 2019

# របកគំហើញ និងកិច្ចពិភាក្សា

| | មិថុនា ២០១៨ ដល់មិថុនា ២០១៩ | កម្ភៈ ២០១៥ ដល់មិថុនា ២០១៩ |
|---|---|---|
| បញ្ចូលទិន្នន័យសរុប | 5144 | 23419 |
| ការបញ្ចូលជាក់លាក់ | 3681 | 10731 |
| អត្រាត្រឹមត្រូវ | 72% | 46% |
| មធ្យមភាគនៃកាបញ្ចូលសកម្មភាពកាប់ឈើខុសច្បាប់ក្នុង១ខែ | 89 | 83 |

1 **តារាង១:** ចំនួននៃការបញ្ចូល អត្រាជាក់លាក់ និងអត្រានៃចំនួននៃការបញ្ចូលលើការកាប់បំផ្លាញព្រៃឈើក្នុងមួយខែកាលពីឆ្នាំកន្លងទៅ និងចំពោះពេលវេលាសរុបដែលអែពព្រៃឡង់បានប្រតិបត្តិការ។ បញ្ហាបច្ចេកទេសជាមួយនឹងអែពក្នុងកំឡុងពេលខែមករានឹងខែកញ្ញា២០១៧ មានន័យថា ចំនួនទិន្នន័យដែលបានបញ្ចូលគឺមានតិច ហើយរយៈពេលនោះគឺមិនបានធ្វើការវិភាគឡើយ។

រវាងខែមិថុនា ២០១៨ ដល់ខែមិថុនា ២០១៩ ប្រពន្ធ័គ្រប់គ្រងទិន្នន័យព្រៃឡង់បានទទួលការបញ្ចូលទិន្នន័យបាន៥១៤៤ ក្នុងចំណោម៣៦៨១ (៧២%) ដោយភ្ជាប់រូបភាពឯកសារ និយាមកា ពេលវេលា និងមានការដាក់ចំណាត់ថ្នាក់។ មានតែទិន្នន័យដែលត្រឹមត្រូវតែប៉ុណ្ណោះដែលបានគិតទៅក្នុងការធ្វើការវិភាគ។ អត្រាត្រឹមត្រូវគឺមានកម្រិតខ្ពស់នៃរយៈពេលបណ្ដុះបណ្ដាលបីដង ពេលវេលាធ្វើការសាកល្បង និងមានសមាជិកថ្មីៗបានចូលរួមល្បាត។ ទោះបីជាពេលបច្ចុប្បន្ន មានការខ្វះថវិកាគាំទ្រការល្បាតទៀងទាត់ ដែលបាននាំទៅរកការធ្វើរបាយការណ៍ពីសកម្មភាពកាប់ឈើខុសច្បាប់ គឺទាបជាងរបាយការណ៍ពីល្បាតបានរាយការណ៍ជាមធ្យម៨០សកម្មភាពកាប់ឈើខុសច្បាប់ក្នុងមួយខែចាប់ពីខែមិថុនា ឆ្នាំ២០១៨ ដល់ខែមិថុនា ឆ្នាំ២០១៩ ប្រៀបធៀបទៅនឹងមធ្យមភាគ៨៣ ករណីកាប់ឈើក្នុងមួយខែ ចាប់តាំងពីគម្រោងបានចាប់ផ្ដើម។ កំណាត់ត្រាដែលបានចុះដោយសមាជិកបណ្ដាញសហគមន៍ព្រៃឡង់
គឺមិនធ្វើធម្មតាដោយការអង្កេតជាញឹកញាប់ឡើយ និងពេលវេលាដែលអង្កេត ទោះជាយ៉ាងណាក៏ដោយ ការល្បាតគឺធ្វើក្នុងពីរខែម្ដង តាមចំនួននឹងថ្ងៃដដែល។
ក្នុងរូបភាពទី៥ បង្ហាញពីការចែកចាយនៃការដាក់បញ្ចូលទិន្នន័យត្រឹមត្រូវ សម្រាប់រយៈពេលចុងក្រោយ។ ទាំងអស់៦៧% បានបញ្ចូលសេចក្ដីរាយការណ៍អំពីធនធាន (ចំនួន ២៤៥៣) ខណៈដែល២៩% គឺស្ដីពីសកម្មភាពកាប់ឈើខុសច្បាប់ (ចំនួន ១០៩០)។ ចំណែកដែលនៅសល់នៃចំណាត់ថ្នាក់ (ប្រែប្រួលអាកាសធាតុ រាយការណ៍ពីប្រតិកម្ម និងផ្សេងៗ ធ្វើឡើង៤% ដោយបានដាក់បញ្ចូល (ចំនួន ១៤៨)។ គំនូសតាងធ្វើការចែករំលែកនៃការបញ្ចូលសម្រាប់ពេលសរុបដែលព្រៃឡង់អែពបានដំណើរការ។




2 **ការបែងចែកការដាក់បញ្ចូលទិន្នន័យ**

រូបភាពទី៥: បង្ហាញការដាក់បញ្ចូលទិន្នន័យសរុប កំឡុងខែមិថុនា ២០១៨ ដល់មិថុនា២០១៩និងកំឡុងខែកុម្ភៈ:២០១៥ដល់មិថុនា២០១៩។







## សកម្មភាព

ក្នុងកំឡុងពេលចន្លោះពីខែមិថុនា ២០១៨ និងខែមិថុនា ២០១៩ សកម្មភាព គឺភាគច្រើនស្ថិតក្នុងចំណាត់ថ្នាក់ទី២។
សកម្មភាពកាប់ឈើខុសច្បាប់ គឺរាបបាន៩៧% បានដាក់បញ្ចូលខណៈដែលសម្បទានរ៉ែ សម្បទានដីសេដ្ឋកិច្ច នេសាទខុសច្បាប់ និងនេសាទខុសច្បាប់ ក៏មានភាគរយតិច។ នេះក៏វាដូចទៅនឹងឯកសារដែលបានធ្វើកាលពីឆ្នាំមុនៗ។
ដូចមានការអធិប្បាយក្នុងរូបភាព៦ ក្នុងចំណាត់ថ្នាក់នៃការកាប់បំផ្លាញព្រៃឈើ ស្ទើរតែពាក់កណ្ដាលនៃការដាក់បញ្ចូលទិន្នន័យក្នុងរបាយការណ៍ គឺគល់ដែលបានកាត់(៤៥%) ជំនួសដោយការកាត់ឈើប្រណីត ដូចជាឈើទាល (រូប៧) កកោះ ផ្ចឹក គឺយកទៅធ្វើគ្រឿងសង្ហារឹម នាំចេញនូវការផលិតដែលជាប្រភេទឈើចុងក្រោយ។ លើសពីនេះ អ្នកត្រួតពិនិត្យគឺបានឆ្លងកាត់ឈើច្រៀករូច (២៤%) (រូបនៅក្រោយ និងនៅក្រូប) ដែលជាធម្មតាបានទុកចោលដោយអ្នកកាត់ឈើដើម្បីត្រឡប់មកយកនៅពេលក្រោយនិងដឹកចេញ។ កាប់ឈូសឆាយ (១២%) បានបង្ហាញផ្ទៃដីធំៗដែលដើមឈើត្រូវបានគេកាត់យក សម្រាប់កសិកម្ម រករ៉ែ ឬសកម្មភាពពង្រីកដី(រូប៨)។ ការកាប់ឆ្ការទាំងនោះ គឺមានទំហំខុសៗគ្នា ប៉ុន្តែរបាយការណ៍ពីមុនបានបង្ហាញថា វាប្រហែលជាទំហំធំដល់ទៅ១០០ហិតា។

កំណាត់គល់ឈើ៤៥%

ឈើបន្ទះ២៤%

ការដឹកជញ្ជូន១៦%

តំបន់ដែលត្រូវបានកាប់បំផ្លាញ ១២%

**ការបញ្ចូលទិន្នន័យកាប់ឈើ** 3

រូបភាពទី៣ ការបែងចែកទិន្នន័យកាប់ឈើជា(%) ចាប់ពីខែមិថុនា ២០១៨ ដល់ខែមិថុនា ២០១៩ និង ខែកុម្ភៈ ២០១៥ ដល់ខែមិថុនា ២០១៩

**រូបភាព៧:**ដង្គត់ដើមឈើទាល (Dipterocarpus alatus Roxb. & G.Don)បានរកឃើញក្នុងពេលល្បាតក្នុងខេត្តស្ទឹងត្រែង ខែមិនា២០១៩។

**រូបភាព៨:** ជាតំបន់បានកាប់រាននៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ ខេត្តស្ទឹងត្រែង ក្នុងខែមករា២០១៩

# ការដឹកជញ្ជូន

5



**រូបភាព១១:** ឡានបាកុងមួយគ្រឿងដឹកឈើខុសច្បាប់ក្នុងខេត្តស្ទឹងត្រែង ខែមករា ២០១៩

6



**រូបភាព១០:** ទប់ស្កាត់គោយន្តដឹកឈើកាប់ខុសច្បាប់ក្នុងខេត្តក្រចេះ ខែកុម្ភៈ ២០១៩

ក៏ជាការប្រមូលទិន្នន័យយ៉ាងច្បាស់លាស់មួយ វាបានបង្ហាញនូវការធ្វើផ្លូវ និងការដឹកជញ្ជូនឈើ ជះឥទ្ធិពលដល់ព្រៃឈើ។ ឧទាហរណ៍ការកាប់ឈើគឺនៅតែដឹកចេញដោយប្រើមាស៊ីនគោយន្ត (៨២% បានបញ្ចូល រូបមុខនិងក្រោយ) ខណៈដែលដឹកតាមម៉ូតូនិងរថយន្ត១៥% (រូប៩)។ យ៉ាងហោចណាស់ការ ពង្រីកនិងជួសជុលផ្លូវទៅកាន់ដែនជម្រកសត្វព្រៃព្រៃឡង់ គឺបានបង្កើនសកម្មភាពកាប់ឈើនេះបើយោងតាមអ្នករស់នៅមូលដ្ឋាន។

ជាមូលដ្ឋានគ្រឹះក្នុងរយៈពេល ៥ឆ្នាំ នៃការប្រមូលទិន្នន័យដោយប្រើអែពព្រៃឡង់ គឺយើងអាចនឹងអង្កេតនូវនិន្នាការ និងកំណត់បាននូវការគម្រាមកំហែងសំខាន់ៗក្នុងព្រៃឡង់។ ប្រៀបធៀបជាមួយរដូវក្តៅកាលពីពីរឆ្នាំកន្លងទៅ យើងអាចមើលឃើញថា មានការកើនឡើងមួយដែលបានរាយការណ៍អំពីសកម្មភាពកាប់ឈើខុសច្បាប់ក្នុងឆ្នាំ ២០១៩ កើនឡើងជាង ២៣%។ រដូវក្តៅនៅកម្ពុជាគឺពីខែធ្នូដល់ខែមេសា (រូបភាព១២)

ការលេចឡើងនូវសេចក្តីរាយការណ៍ពីសកម្មភាពកាប់បំផ្លាញព្រៃឈើ ជាសកម្មភាពបន្ទាន់រួមគ្នាមួយដើម្បីប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់។

--------------------------------

12 Plough machine or goh-yun in Khmer is a tractor and the most used means of forest transport

## ④ ទិន្នន័យការដឹកជញ្ជូន

រូបភាពទី៩: ការបង្ហាញនៃសកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ក្នុងខែមិថុនា២០១៨ ដល់ខែមិថុនា ២០១៩ក៏ដូចជា ខែកុម្ភៈ២០១៥ ដល់មិថុនា ២០១៩




## ⑤ បញ្ចូលទិរដូវប្រាំង

រូបភាព១២៖ ការប្រៀបធៀបនៃការកត់ត្រានូវសកម្មភាពក្នុងកំឡុងរដូវប្រាំង២០១៨ និង២០១៩(រដូវប្រាំង:ខែធ្នូដល់ខែមេសា)









ធនធាន

រូបភាព១៦:ដើមចំបក់ (Irvingia malayana Oliv. ex A.W.Benn.).

រូបភាព១៥: ដើមឈើទាលA (Dipterocarpus alatus Roxb. & G.Don)

រូបភាព១៣ បង្ហាញការកត់ត្រាធនធានក្នុងកំឡុងខែមិថុនា ២០១៨ ដល់មិថុនា ២០១៩។ ក្នុងការបញ្ចូលព័ត៌មានទាំងអស់គឺភាគច្រើនជាដើមឈើ (បញ្ចូល២១១៣) តាមដោយអនុផលព្រៃឈើ (បញ្ចូល២៧៣) ។ នៅសល់ចំណាត់ថ្នាក់២ទៀតគឺសត្វព្រៃ (បញ្ចូល៨៤) និងតំបន់ជំនឿ (បញ្ចូល២)។ ភាគរយនេះគឺដូចគ្នាទៅនឹងលទ្ធផលកំឡុងខែកុម្ភៈ ២០១៥ ដល់ខែមិថុនា ២០១៩។ រូបភាព១៤ បង្ហាញអំពីប្រភេទពូជឈើ។ ភាគច្រើនរាយការណ៍នូវដើមឈើទាល (រូបភាព១៥) ដែលប្រើសម្រាប់យកជ័រ។ យោងទៅតាមបណ្ដាញសហគមន៍ព្រៃឡង់ ដើមឈើប្រភេទនេះគឺត្រូវបានគេកាត់ជាញឹកញាប់ (រូប៧) និងជាប្រភេទជិតផុតពូជ នេះបើយោងតាម IUCN ក្នុងបញ្ជីក្រហម។ នៅលំដាប់ទីពីរ គឺបានរាយការណ៍ និងទី៣គឺអំពីការកាប់ឈើ ជាប្រភេទផ្ដៀក គឺជាប្រភេទជិតផុតពូជដែរ។ ប្រភេទ៣គឺប្រភេទចំបក់ (រូប១៦)។ ជាទូទៅ ៤/១០ គឺជាពូជឈើដែលនៅក្នុងបញ្ជីក្រហមរបស់ IUCN។ ភាគច្រើននៅក្នុងព្រៃឡង់គឺមានពូជឈើច្រើនជាគុណតម្លៃក្នុងការអភិរក្ស ប៉ុន្តែប្រភេទទាំងនេះកំពុងតែទទួលរងការគម្រាមពីកាប់បំផ្លាញ។







## ⑥ ទិន្នន័យធនធានធម្មជាតិ

**រូបភាពទី៦** ការបញ្ចូលទិន្នន័យ ការចែកចាយធនធានមានតម្លៃ ចាប់ពីខែ ឆ្នាំមិថុនា ២០១៨ ដល់ខែមិថុនា ឆ្នាំ២០១៩ និង ខែកុម្ភៈ ឆ្នាំ២០១៥ ដល់ខែ មិថុនា ឆ្នាំ២០១៩



ការដាក់បញ្ចូលទិន្នន័យធនធានពីខែមិថុនា ២០១៨ ដស់មិថុនា ២០១៩២០១៩



ការដាក់បញ្ចូលទិន្នន័យធនធានខែកុម្ភៈ ២០១៥ ដស់មិថុនា ២០១៩

## ⑦ ឈ្មោះឈើភាគច្រើន ដែលបានកត់ត្រា

**រូបភាព១៤:** ប្រភេទឈើភាគច្រើនត្រូវបានរាប់ជាចំនួនមួយនៃការកត់ត្រាចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០១៥

**638 ដើមឈើទាល** Chhertheal (Resin)
*Dipterocarpus alatus Roxb. & G.Don*
**439 ដើមផ្ដៀក** Pdeak
*Anisoptera costata Korth.*
**331 ដើមចំបក់** Chombork
*Irvingia malayana Oliv. ex A.W.Benn.*
**233** Korkoh
*Sindora siamensis Miq.*
**141 ដើមស្រឡៅ** Sralao'
*Lagerstroemia calyculata Kurz*
**101 ដើមមៀនព្រៃ** Mean/Meanprey
*Dimocarpus longan Lour.*
**98 ដើមដូងចែម** Doungchem
*Heritiera javanica (Blume) Kosterm.)*
**70 ដើមត្រាច** Trach (Resin)
*Dipterocarpus intricatus Dyer*
**64 ដើមពពែល** Porpael
*Shorea roxburghii G. Don*
**62 ដើមច្រម៉ាស់** Chrormas
*Vatica odorata (Griff.) Symington*
**60 ដើមពង់** Paong
*Calophyllum calaba var. bracteatum (Wight) P.F.Stevens*

ភាគច្រើនរាយការណ៍ពីអនុផលព្រៃឈើបង្ហាញក្នុងរូបភាព១៧។ ខាន់ម៉ា ឬ ខ្ទង់ (រូប១៨) គឺជាពូជរុក្ខ    ជាតិ។ ខ្ទង់គឺជារុក្ខជាតិឱសថប្រើជាទឹកតែជួយព្យាបាលជម្ងឺរាគ និងដើមវល្លិ៍ប្រើសម្រាប់ត្បាញកន្ត្រក កន្ទេល និងគ្រឿងសង្ហារឹម ឬជាស្បូវប្រក់ដំបូល។ សំខាន់បំផុត ខ្ទង់គឺធ្វើចង្អេរអុំស្រវ។ លំដាប់ទី២ជាពួកអនុផល ច្នូ មានរាងដូចខ្ទង់ដែរ។ ផ្នែកទី៣គឺអង្រែដែក មានសារជាតិឱសថច្រើន។

ឧទាហរណ៍ ស្លឹកវាដាំទឹកដូចទឹកតែគឺជួយឲ្យឈាមរត់ស្រួល។ លើសពីនេះ បើផ្សំដោយយកស្លឹក និងផ្កានៃដើមច្នូ គឺជួយដល់ស្ត្រីពេលសម្រាលកូនវាព្យាបាលបំប៉ននិងជួយបង្កើនទឹកដោះ។ ជាចុងក្រោយ ស្លឹកខ្ចីៗគឺត្រូវថ្នាំ និងដើមវាសម្រាប់ច្រៀក។

## 8 ឈ្មោះអនុផលព្រៃឈើភាគច្រើន ដែលបានកត់ត្រា

រូបភាព១៧: ប្រភេទអនុផលព្រៃឈើភាគច្រើន ត្រូវបានរាប់ជាចំនួនមួយនៃការកត់ត្រាចាប់តាំងពីខែកម្ភៈ ឆ្នាំ២០១៥




**37 ដើមខ្ទង់ឬខាន់ម៉ា** Ktong (Medicinal)
*(Ancistrocladus tectorius (Lour.) Merr.)*
**35 វល្លិ៍ច្នូ** Chnou (Crafts)
*(Myrialepis paradoxa (Kurz) J. Dransf.)*
**29 ដើមអង្រែដែក** Angraedaek (Medicinal)
*(Dracaena angustifolia (Medik.) Roxb.)*
**25 ផ្សិត** Mushrooms (Edible)
(Different species)
**15 វល្លិ៍សោម** Saom (Edible)
*(Daemonorops jenkinsiana (Griff.) Mart.)*
**13 ដើមអន្ទង់ស** Antong Sor (Medicinal)
*(Eurycoma longifolia Jack)*
**12 ដើមវល្លិ៍គុយ** Resin (Crafts)
**12 ដើមផ្អាវ** Paav (Edible)
*(Licuala spinosa Wurmb)*
**6 ដើមច្នាប** Chnarb (Crafts)
*(Areca triandra Roxb. ex Buch.-Ham.)*
**6 ដើមត្រមូង** Trormoong (Edible)
*(Garcinia oliveri Pierre)*
**5 ដើមស្មាច់** Smarch (Edible)
*(Syzygium zeylanicum (L.) DC.)*

9


រូបភាព១៩: ដើមអ័រគីដេ ជាសណ្ដានរបស់ Vanda

## ទិន្នផលព្រៃឈើដែលមិនមែនជាដើមឈើ

10


រូបភាព១៨: ដើមខ្ទង់ ឬខាន់ម៉ា(Ancistrocladus tectorius (Lour.) Merr.)

# ការផ្តល់អនុសាសន៍ដោយបណ្តាញសហគមន៍ព្រៃឡង់

យើងខ្ញុំទាំងអស់គ្នាជាសមាជិកបណ្តាញសហគមន៍ព្រៃឡង់ទាំងបួនខេត្ត ក្រចេះ

## ស្ទឹងត្រែង ព្រះវិហារ និងកំពង់ធំ ដែលកំពុងធ្វើការងារស្ម័គ្រចិត្តការពារ ព្រៃការពារដែនជម្រកសត្វព្រៃ ព្រៃឡង់ សូមសាទរ និងគាំទ្រ ចំពោះចំណាត់ការរបស់ គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ក្រសួងបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធ ក្នុងកិច្ចការបង្ក្រាបបទល្មើសព្រៃឈើ និងការស្តារព្រៃឡើងវិញ។

យើងខ្ញុំទាំងអស់គ្នាបានតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងបុព្វហេតុការពារធនធានធម្មជាតិ និងការស្តារព្រៃឈើឡើងវិញ។ នៅក្នុងរយៈពេលថ្មីៗនេះយើងខ្ញុំបានសង្កេតឃើញថា គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ក្រសួងបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធបានធ្វើសកម្មភាពយ៉ាងខ្លាំងក្លា រហូតមានការចាប់ខ្លួន(មេជួញដូរឈើធំៗ និងមន្ត្រីដែលពាក់ព័ន្ធបទល្មើស)ជាច្រើននាក់ ការបិទ(ទីតាំងស្តុកឈើ រោងម៉ាស៊ីនកែឆ្នៃឈើ និងរោងសិប្បកម្មកែឆ្នៃឈើ)ជាច្រើនកន្លែង ការរឹបអូសឈើជាច្រើនពាន់ម៉ែត្រគូប និងការរឹបអូសនិងកំទេចមធ្យោបាយកាប់និងដឹកជញ្ជូនឈើជាច្រើនរយគ្រឿង។ សកម្មភាពបង្ក្រាបទាំងនេះ បាននិងកំពុងបន្តជាហូរហែឥតស្រាកស្រាន្ត ដើម្បីការពារព្រៃឈើដែលនៅសេសសល់។

មួយវិញទៀត យើងខ្ញុំក៏បានសង្កេតឃើញ ស្របពេលសកម្មភាពបង្ក្រាបបទល្មើសព្រៃឈើកំពុងបន្តជាហូរហែ គឺសកម្មភាពដឹកនាំការដាំកូនឈើឡើងវិញជាច្រើនម៉ឺនដើម ដោយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត បានបង្ហាញឱ្យឃើញនូវការប្តេជ្ញាចិត្ត របស់រាជរដ្ឋាភិបាលក្នុងបុព្វហេតុអភិរក្សធនធានធម្មជាតិនៅកម្ពុជា។

យើងខ្ញុំជឿជាក់យ៉ាងមុតមាំចំពោះសកម្មភាពស្តារព្រៃឈើឡើងវិញ និងវិធានការបង្ក្រាបបទល្មើសព្រៃឈើនឹងនៅតែបន្តរហូតបញ្ចប់រាល់បទល្មើសគ្រប់រូបភាព និងសង្ឃឹមយ៉ាងមុតមាំចំពោះ គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ នឹងមានវិធានការបិទរោងម៉ាស៊ីនអារកែច្នៃឈើ និងផលិតក្តារបន្ទះ របស់ក្រុមហ៊ុន ស៊ីង បាយអូ ថេក (ខេមបូឌា) ខូអិលធីឌី នៅចំណុចភូមិសាស្ត្រភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ។

យើងខ្ញុំទាំងអស់គ្នាមានក្តីសោមនរីករាយក្រៃលែង និងសូមបួងសួងដល់វត្ថុសក្តិសិទ្ធ តាមថែរក្សាការពារមន្ត្រីគ្រប់រូប ដៃគូអភិវឌ្ឍ អ្នកសារព័ត៌មាន និងសហគមន៍ ដែលកំពុងបំពេញបេសសកកម្មការពារធនធានធម្មជាតិ ឱ្យជួបប្រទះតែនឹងសេចក្តីសុខសុវត្ថិភាពគ្រប់ពេលវេលា និងទទួលបានជោគជ័យគ្រប់ភារកិច្ចកុំបីឃ្លៀងឃ្លាតឡើយ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតំណាងសហគមន៍តាមរយៈលេខទូរស័ព្ទដូចខាងក្រោម៖

**១. លោក ឯក សុវណ្ណា** ០៩៧ ៦៤៤ ៩៩៩៨/០៩៨ ៨៤៥ ៩៧៩
**២. លោក ស្រី ថី** ០៩៩ ៧២២ ១៨៧
**៣. លោក ម៉ិញ នី** ០៩៦ ៣០០ ២៧៦២
**៤. កញ្ញា ឈាង លី** ០៩៦ ៦៦៨ ០៦៧៣



**រូបក្របមុខ:** ទប់ស្កាត់គោយន្តដឹកជញ្ជូនឈើខុសច្បាប់ ក្នុងខេត្តក្រចេះ (កុម្ភៈ ២០១៩)

**រូបភាពក្របខាងក្រោយ:** ល្បាតរបស់បណ្តាញសហគមន៍ព្រៃឡង់ធ្វើសេចក្តីរាយការណ៍នៃចម្រៀកឈើបានរកឃើញក្នុងតំបន់មួយ ក្នុងខេត្តក្រចេះ (មេសា ២០១៩)



# ចូលរួមការពារ ព្រៃឡង់ ទាំងអស់គ្នា

ព័ត៌មានដែលដាក់បញ្ចូលក្នុងឯកសារនេះ គឺជាកម្មសិទ្ធិបញ្ញារបស់បណ្តាញសហគមន៍ព្រៃឡង់។ យើងសូមស្វាគមន៍ដល់ការប្រើប្រាស់ ដកស្រង់ និងការចែកចាយនូវឯកសារនេះ ដែលបានផ្តល់ជាប្រភពនៃឯកសារយោងផង។

សាកលវិទ្យាល័យ កប់ប៉ិនហាហ្កែន (University of Copenhagen) បានអញ្ជើញក្រសួងបរិស្ថានដើម្បីធ្វើអត្ថាធិប្បាយលើឯកសារនេះ ហើយបានទទួលចម្លើយត្រឡប់ដូចតទៅ៖ "ក្រសួងបរិស្ថាន គឺមិនមានជំហរណាមួយក្នុងការផ្តល់អត្ថាធិប្បាយលើសេចក្តីព្រាងរបាយការណ៍នេះឡើយ។"
បណ្តាញសហគមន៍ព្រៃឡង់សូមធ្វើការថ្លែងអំណរគុណ ដល់មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវរួមគ្នា ( មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវរួមគ្នា នៃសហគមន៍អឺរុប) ដែលបានគាំទ្រនូវបច្ចេកទេសដើម្បីចែករំលែកដោយប្រើឧបករណ៍ FCDM បង្ហាញនូវការបាត់បង់និងប៉ះពាល់ដល់គម្របព្រៃឈើ អ្នកធ្វើការហាត់ការមកពីសាកលវិទ្យាល័យកប់ប៉ិនហាហ្កែន និងថ្លែងអំណរគុណដល់អ្នកគ្រប់គ្នាដែលបានស្ម័គ្រចិត្តជួយជ្រោមជ្រែង។ របាយការណ៍នេះនឹងមិនអាចចប់សព្វគ្រប់ឡើយ ប្រសិនបើគ្មានការគាំទ្រពីពួកគាត់ទាំងអស់គ្នា។
ព្រៃឡង់អែពបានកសាងឡើងផ្អែកទៅលើកម្មវិធី Sapelli ជាគម្រោងបើកទូលាយដែលសម្របសម្រួលដល់ការប្រមូលព័ត៌មានតាមភាសាខុសគ្នា និងអ្នកមិនចេះអក្សរ តាមរយៈការកំណត់បាននូវរចនាសម្ព័ន្ធដែលដំណើរការដោយរូបភាពតំណាងប្រទាក់ចំណុចគ្នា។ សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់ : http://www.sapelli.org/
រូបភាពទាំងអស់ គឺជាកម្មសិទ្ធិបញ្ញារបស់បណ្តាញសហគមន៍ព្រៃឡង់
ផែនទីទាំងអស់ដែលបានធ្វើគឺប្រើប្រាស់ QGIS.៣.៦.២
ការបង្កើតក្រាហ្វិកនិងពត៌មានក្រាហ្វិកគឺបានរៀបចំដោយ Carolina Salassa
ⓒ
ឯកសារនេះគឺត្រូវបានការពារដោយ(CC BY-NC ៤.០)
មានផ្នែកមួយគឺជាការគាំទ្រថវិកាពីមូលនិធិ The Alexander Soros
កំណែលើកទី១ ក្នុងខែកញ្ញា២០១៩

PREY LANG
www.preylang.net
Copyright © PLCN 2019-2020